**អង្គការសហប្រជាជាតិ**

**ក្រុមប្រឹក្សាសន្តិសុខ**

ចំលងជូនៈ ទូទៅ

ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០០០

.................................................................................................................................................

## សេចក្តីសំរេចលេខ ១៣២៥ (២០០០)

អនុម័តដោយក្រុមប្រឹក្សាសន្តិសុខ ក្នុងកិច្ចប្រជុំលើកទី៤២១៣ នៅថ្ងៃទី ៣១ ខែតុលាឆ្នាំ២០០០

ក្រុមប្រឹក្សាសន្តិសុខ

យោងតាមសេចក្តីសំរេចលេខ ១២៦១ (១៩៩៩) នាថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៩, លេខ១២៦៥ (១៩៩៩) នាថ្ងៃទី១៧ ខែកញ្ញា ១៩៩៩, លេខ១២៩៦ (២០០០) នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ និងលេខ ១៣១៤ (២០០០) នាថ្ងៃទី១១ ខែសីហា ឆ្នាំ២០០០ ព្រមទាំងសេចក្តីថ្លែងការដែលពាក់ព័ន្ធដ៏ទៃទៀត របស់ប្រធានាធិបតី និងយោងតាមសេចក្តីថ្លែងការរបស់ប្រធានាធិបតីទៅកាន់សារព័ត៌មាននៅក្នុងឱកាសនៃទិវានារីអន្តរជាតិ និងសន្តិភាពអន្តរជាតិរបស់អង្គការសហប្រជាជាតិ នាថ្ងៃទី៨ ខែមិនា ឆ្នាំ២០០០ (SC/៦៨១៦)

យោងតាមសេចក្តី ប្រកាសក្រុងប៉េកាំង និងវេទិការសកម្មភាព (A/៥២/២៣១) រួមទាំងសេចក្តីប្រកាសទាំងឡាយណាដែលមាននៅក្នុងលទ្ធផលនៃកិច្ចប្រជុំពិសេសលើកទី២៣ របស់សភាជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ ក្រោមប្រធានបទស្តីពី "ស្ត្រីឆ្នាំ២០០០ : សមធមិយេនឌ័រ ការអភិវឌ្ឍន៍ និងសន្តិភាពសំរាប់សតវត្សទី២១" (A/S-23/10/Rev.1) ជាពិសេសឯកសារទាំងឡាយណាដែលពាក់ព័ន្ធនឹងស្ត្រី និងជំលោះប្រដាប់អាវុធ ។

កត់សំគាល់នូវគោលបំណង និងគោលការណ៍របស់ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ និងទំនួលខុសត្រូវជាចំបងរបស់ក្រុមប្រឹក្សាសន្តិសុខដែលស្ថិតក្រោមធម្មនុញ្ញសំរាប់ការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ

សំដែងនូវកង្វល់ដែលថាជនស៊ីវិល ជាពិសេសស្ត្រី និងកុមារ រាប់បញ្ចូលទាំងមនុស្សភាគច្រើនបំផុតដែលមិនអាចគេចផុតពីភាពរងគ្រោះដែលបង្កដោយជម្លោះប្រដាប់អាវុធ រួមមានជនភៀសខ្លួន និងជននៅក្នុងប្រទេសដែលត្រូវគេដេញចេញពីកន្លែងរស់នៅ អ្នកដែលជាគោលដៅវាយប្រហាររបស់ពួកយុទ្ធជននិងជនប្រដាប់អាវុធ និងការទទួលស្គាល់ ផលប៉ះពាល់ចំពោះសន្តិភាពដ៏យូរអង្វែង និងការផ្សះផ្សារជម្លោះ

ការអះអាងសារជាថ្មីចំពោះតួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងការទប់ស្កាត់និងការដោះស្រាយជម្លោះ និងក្នុងការកសាងសន្តិភាព ព្រមទាំងសង្កត់ធ្ងន់លើភាពសំខាន់នៃការចូលរួមប្រកបដោយសមធមិ និងការចូលរួមដ៏ពេញលេញក្នុងកិច្ចប្រឹងប្រែងដើម្បីការលើកកំពស់និងការរក្សាសន្តិភាពនិងសន្តិសុខ និងភាពចាំបាច់ក្នុងការ បង្កើនតួនាទីនៃការធ្វើការសំរេចចិត្តដែលទាក់ទងទៅនឹងការទប់ស្កាត់ និងការដោះស្រាយជម្លោះ

ការអះអាងសារជាថ្មីផងដែរនូវភាពចាំបាច់ក្នុងការអនុវត្តអោយបានពេញលេញនូវច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធមិអន្តរជាតិ ដែលការពារសិទ្ធិរបស់ស្ត្រី និងកុមារី ក្នុងពេលមានជម្លោះ និងបន្ទាប់ពីជម្លោះ

00-72018 (E)

ការសង្កត់ធ្ងន់ទៅលើភាពចាំបាច់ចំពោះភាគីទាំងអស់ក្នុងការធានាថា កម្មវិធីបោសសំអាតមីន និងលើកកំពស់ការយល់ដឹងអំពីមីន និងយកចិត្តទុកដាក់គិតគូរអំពីតំរូវការពិសេសរបស់ស្ត្រី និងកុមារីផងដែរ ។

ការទទួលស្គាល់តំរូវការជាបន្ទាន់ក្នុងការបញ្ជ្រាបទស្សនៈយេនឌ័រទៅក្នុងប្រតិបត្តិការរក្សាសន្តិភាព និងការកត់សំគាល់នូវសេចក្តីប្រកាសវីនហុក (Windhoek) និង ផែនការសកម្មភាពណាមីប្បៀ (Namibia) នៃការបញ្ជ្រាបទស្សនៈយេនឌ័រនៅក្នុងប្រតិបត្តិការគាំទ្រសន្តិភាពប្រកបដោយពហុវិសាលភាព (S/2000/693) ។

ការទទួលស្គាល់ផងដែរនូវខ្លឹមសារនៃអនុសាសន៏ ដែលមាននៅក្នុងសេចក្តីថ្លែងការរបស់ប្រធានាធិបតីរបស់ខ្លួនទៅកាន់សន្និសិទសារព័ត៌មាន នៅថ្ងៃទី៨ខែមិនាឆ្នាំ២០០០ សំរាប់វគ្គបណ្តុះបណ្តាលជំនាញ សំរាប់បុគ្គលិករក្សាសន្តិភាពទាំងអស់ ស្តីពី កិច្ចការពារតំរូវការពិសេស និងសិទ្ធិមនុស្សរបស់ស្ត្រី និងកុមារ ក្នុងស្ថានភាពជម្លោះ

ការទទួលស្គាល់ថា ការយល់ដឹងអំពីផលប៉ះពាល់របស់ជម្លោះប្រដាប់អាវុធ មកលើស្ត្រី និងកុមារី ការរៀបចំស្ថាប័នប្រកបដោយប្រសិទ្ធភាពដើម្បីធានាចំពោះកិច្ចការពារ និងការចូលរួមពេញលេញនៅក្នុងដំនើរការសន្តិភាព អាចរួមចំណែកដ៏ធំធេងចំពោះ ការរក្សា និងការលើកកំពស់សន្តិភាព និងសន្តិសុខអន្តរជាតិ ។

ការកត់សំគាល់ពីភាពចាំបាច់ក្នុងការប្រមូលទិន្នន័យអំពីផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធ ដែលមានចំពោះស្ត្រី និងកុមារី

១. ជំរុញប្រទេសសមាជិកទាំងអស់អោយបង្កើនភាពតំណាងរបស់ស្ត្រី នៅគ្រប់កំរិតនៃការសំរេចចិត្តនៅក្នុងស្ថាប័នថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ និងយន្តការសំរាប់ការទប់ស្កាត់ ការគ្រប់គ្រង និងការដោះស្រាយជម្លោះ

២. លើកទឹកចិត្តអគ្គលេខាធិការ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាព (A/49/587) ដោយតំរូវអោយមានការបង្កើនការចូលរួមរបស់ស្ត្រីនៅគ្រប់កំរិតនៃការសំរេចចិត្ត នៅក្នុងការដោះស្រាយជម្លោះ និងដំណើរការសន្តិភាព

៣. ជំរុញអគ្គលេខាធិការ ក្នុងការតែងតាំងស្ត្រីអោយបានកាន់តែច្រើន ជាអ្នកតំណាងពិសេស និងប្រេសិតដើម្បីកាន់តំណែងល្អៗ តំណាងអោយអគ្គលេខាធិការ និងតំរូវអោយប្រទេសសមាជិកទាំងអស់ ផ្តល់បេក្ខជនទៅអោយអគ្គលេខាធិការ ដើម្បីបញ្ចូលឈ្មោះរបស់ពួកគេក្នុងបញ្ជីឈ្មោះកណ្តាលដែល ត្រូវបានធ្វើការពិនិត្យកែតំរូវប្រកបដោយនិយ័តភាព

៤. បន្តជំរុញអគ្គលេខាធិការ ក្នុងការស្វះស្វែងពង្រីកតួនាទី និងការរួមចំណែករបស់ស្ត្រី នៅក្នុងប្រតិបត្តិការការងារជាក់ស្តែងរបស់អង្គការសហប្រជាជាតិ និង ជាពិសេសនៅក្នុងចំណោមអ្នកសង្កេតការណ៍យោធា នគរបាលស៊ីវិល បុគ្គលិកសិទ្ធិមនុស្ស និងបុគ្គលិកមនុស្សធម៌

៥. សំដែងនូវឆន្ទៈរបស់ខ្លួន ក្នុងការផ្សាភ្ជាប់ទស្សនៈយេនឌ័រជាមួយប្រតិបត្តិការរក្សាសន្តិភាព និងជំរុញអគ្គលេខាធិការ ក្នុងការធានាថាសមាសធាតុយេនឌ័រ ត្រូវបានរួមបញ្ចូលនៅក្នុងប្រតិបត្តិការការងារជាក់ស្តែងផងដែរ នៅក្នុងស្ថានភាពសមរម្យណាមួយ

៦. ស្នើអោយអគ្គលេខាធិការ ផ្តល់ជូនប្រទេសសមាជិក នូវសេចក្តីណែនាំអំពីការបណ្តុះបណ្តាល និងសម្ភារៈអំពីការការពារសិទ្ធិនិងតំរូវការដោយឡែកមួយចំនួនរបស់ស្ត្រី និងអំពីភាពសំខាន់ដោយបញ្ចូលស្ត្រីដែលសកម្មទៅក្នុងការចូលរួមនៅក្នុងវិធានការកសាងសន្តិភាពនិងរក្សាសន្តិភាពទាំងអស់ ដោយអញ្ជើញ ប្រទេសសមាជិកទាំងអស់បញ្ចូលធាតុទាំងនេះរួមទាំងការបណ្តុះបណ្តាលពីការយល់ដឹង ពីមេរោគអេដស៍/ជំងឺអេដស៍ ក្នុងកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិទៅដល់យោធានិងបុគ្គលិកនគបាលស៊ីវិល មុនពេលពួកគេចាប់ផ្តើមបំពេញការងារ និងបន្តស្នើអគ្គលេខាធិការអោយធានាថាបុគ្គលិកស៊ីវិលនៃក្រុមប្រតិបត្តិការរក្សាសន្តិភាពទទួលបាននូវការបណ្តុះបណ្តាលស្រដៀងគ្នានេះដែរ ។

៧. ជំរុញអោយប្រទេសសមាជិកទាំងអស់បង្កើនការគាំទ្រផ្នែកភស្តុភារ បច្ចេកទេស និងហិរញ្ញវត្ថុដោយស្ម័គ្រចិត្ត សំរាប់កិច្ចប្រឹងប្រែងបណ្តុះបណ្តាលផ្នែកការយល់ដឹងអំពីយេនឌ័រ រួមទាំងការបណ្តុះបណ្តាលដែលឧបត្ថម្ភដោយជំនួយថវិកា និងកម្មវិធីដែលពាក់ព័ន្ធ និងអង្គភាពពាកព័ន្ធដ៏ទៃទៀត រួមមានជំនួយថវិកាអង្គការសហប្រជាជាតិសំរាប់ស្ត្រី ជំនួយថវិកាអង្គការសហប្រជាជាតិសំរាប់កុមារនិងការិយាល័យរបស់ ស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិដើម្បីជនភៀសខ្លួន និងស្ថាប័នពាក់ព័ន្ធដទៃទៀត ។

៨. ស្នើអោយមានការចូលរួមពីគ្រប់វិស័យដែលពាក់ព័ន្ធទាំងអស់ នៅខណៈពេលកំពុងចរចារ និងអនុវត្តកិច្ចព្រមព្រៀងសន្តិភាព ដើម្បីបញ្ចូលទស្សនៈយេនឌ័រ រួមទាំងទស្សនៈដទៃទៀតដូចជា :

ក. តំរូវការពិសេសរបស់ស្ត្រី និងកុមារី ក្នុងកំឡុងពេលធ្វើមាតុភូមិនិវត្ត និងការតាំងទីលំនៅថ្មី និងសំរាប់ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងការកសាងឡើងវិញក្រោយជម្លោះ

ខ. វិធានការគាំទ្រគំនិតផ្តួចផ្តើមសន្តិភាពរបស់ស្ត្រីនៅក្នុងមូលដ្ឋាន និងដំនើរការអន្តោគ្រាមដើម្បីការដោះស្រាយជម្លោះ និងការចូលរួមរបស់ស្ត្រីនៅក្នុងគ្រប់យន្តការអនុវត្តន៏នៃកិច្ចព្រមព្រាងសន្តិភាព

គ. វិធានការដែលធានានូវកិច្ចការពារ និងការគោរពសិទ្ធិមនុស្ស របស់ស្ត្រី និងកុមារី ជាពិសេសនៅខណៈដែល វិធានការទាំងនេះជាប់ពាក់ព័ន្ធទៅនឹងរដ្ឋធម្មនុញ្ញ ប្រព័ន្ធបោះឆ្នោត នគរបាល និងតុលាការ

៩. ស្នើអោយភាគីដែលមានជម្លោះប្រដាប់អាវុធទាំងអស់ គោរពអោយបានពេញលេញនូវច្បាប់អន្តរជាតិដែលអាចអនុវត្តបានចំពោះសិទ្ធិ និងកិច្ចការពារដល់ស្ត្រី និងកុមារី ជាពិសេសជនស៊ីវិល និងដោយឡែកកាតព្វកិច្ច ដែលត្រូវមានចំពោះពួកគាត់ ស្របតាមអនុសញ្ញាហ្សឺណែវ ឆ្នាំ១៩៤៩ និង ពិធីសារបន្ថែមឆ្នាំ១៩៧៧ អនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១ និងពិធីសារឆ្នាំ១៩៦៧ អនុសញ្ញាស្តីពីការលុបបំបាត់នូវរាល់ទំរង់នៃការរើសអើងចំពោះស្ត្រីឆ្នាំ១៩៧៩ និងពិធីសារជម្រើសឆ្នាំ១៩៩៩ និង អនុសញ្ញាអង្គការ

សហប្រជាជាតិស្តីពីសិទ្ធិកុមារឆ្នាំ១៩៨៩ និង ពិធីសារជម្រើសពីរដែលបានធ្វើឡើង នៅថ្ងៃទី២៥ ខែឧសភាឆ្នាំ២០០០ និងដើម្បីចងចាំនូវមាត្រាច្បាប់ដែលពាក់ព័ន្ធរបស់លក្ខន្តិកៈក្រុងរ៉ូម របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ

១០. ស្នើអោយភាគីដែលមានជម្លោះប្រដាប់អាវុធទាំងអស់ចាត់វិធានការពិសេស ដើម្បីការពារស្ត្រី និងកុមារីអោយរួចផុតពីការរងនូវការប្រើអំពើហិង្សាដែលបណ្តាលមកបញ្ហាយេនឌ័រ ជាពិសេសការរំលោភ សេពសន្ថវៈ និងទំរង់នៃការរំលោភបំពានផ្លូវភេទដទៃទៀត និងរាល់ទំរង់នៃអំពើហិង្សានៅក្នុងស្ថានភាពដែលមានជម្លោះប្រដាប់អាវុធ

១១. សង្កត់ធ្ងន់លើការទទួលខុសត្រូវរបស់ប្រទេសទាំងអស់ក្នុងការបញ្ចប់និទណ្ឌភាព និងកាត់ទោសជនទាំងឡាយដែលទទួលខុសត្រូវចំពោះរបបប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដោយរាប់បញ្ចូលទាំងជនទាំងឡាយដែលពាក់ព័ន្ធនឹងអំពើហិង្សាលើផ្លូវភេទរឺអំពើហិង្សាផ្សេងៗទៅលើស្ត្រីនិងកុមារី និង ផ្តោតការយកចិត្តទុកដាក់ចំពោះភាពចាំបាច់ក្នុងការដកបទឧក្រិដ្ឋកម្មទាំងនេះចេញពីមាត្រាច្បាប់ដែលថែងពីការលើកលែងទោស អោយអស់ពីលទ្ធភាព

១២. ស្នើអោយភាគីដែលមានជម្លោះប្រដាប់អាវុធទាំងអស់គោរពជនស៊ីវិល និងលក្ខណៈមនុស្សធម៌ របស់ជំរុំជនភៀសខ្លួន និងកន្លែងជ្រកកោនដទៃទៀត និងគិតគូរពិចារណាអំពីតំរូការជាពិសេសរបស់ស្ត្រីនិងកុមារី ដែលមានបញ្ចូលនៅក្នុងការតាក់តែង និងការរំលឹកឡើងវិញនូវ សេចក្តីសំរេច លេខ១២០៨ (ឆ្នាំ១៩៩៨) ចុះថ្ងៃទី១៩ខែវិច្ឆិកាឆ្នាំ១៩៩៨ និងលេខ១២៩៦ (ឆ្នាំ២០០០) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០

១៣. លើកទឹកចិត្តភាគីទាំងអស់ដែលចូលរួមនៅក្នុងការរៀបចំផែនការសំរាប់ការទំលាក់អាវុធ ការរំសាយកងទ័ព និងសមាហរណកម្ម អោយពិចារណាអំពីតំរូវការដោយឡែករបស់អតីតយុទ្ធជននិងអតីត យុទ្ធនារី និងគិតគូអំពីតំរូវការរបស់សមាជិកគ្រួសារក្នុងបន្ទុករបស់ពួកគេ។

១៤. បញ្ជាក់សាជាថ្មីនូវការត្រៀមខ្លួនអោយបានរួចរាល់ នៅខណៈណាដែលវិធានការទាំងនេះ ត្រូវបានយកមកអនុវត្ត ដោយស្របតាមមាត្រា៤១ របស់ធម្មនុញ្ញអង្គការសហប្រជាជាតិ ដើម្បីពិចារណាដល់ផលប៉ះពាល់ដែលអាចកើតមានចំពោះប្រជាជនស៊ីវិល ដោយការចងចាំជានិច្ចនូវតំរូវការពិសេសរបស់ ស្ត្រីនិងកុមារី ដើម្បីគិតពិចារណាចំពោះករណីលើកលែងប្រកបដោយលក្ខណៈមនុស្សជាតិដ៏សមរម្យ

១៥. បង្ហាញអំពីឆន្ទៈរបស់ខ្លួនក្នុងការធានាថាបេសកកម្មក្រុមប្រឹក្សាសន្តិសុខបានគិតគូរអំពីយេនឌ័រ និងសិទ្ធីស្ត្រី តាមរយៈការប្រឹក្សាយោបល់ជាមួយក្រុមស្ត្រីនៅក្នុងមូលដ្ឋាន និងអន្តរជាតិ ។

១៦. កោះអញ្ជើញអគ្គលេខាធិការអង្គការសហប្រជាជាតិដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់របស់ជម្លោះប្រដាប់អាវុធ ទៅលើស្ត្រីនិងកុមារី តួនាទីស្ត្រីនៅក្នុងការកសាងសន្តិភាពនិងវិសាលភាពយេនឌ័រ

នៃដំនើរការសន្តិភាពនិងការដោះស្រាយជម្លោះ និងថែមទាំងស្នើសុំអោយ អគ្គលេខាធិការបញ្ជូនរបាយការណ៍ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះមកកាន់ក្រុមប្រឹក្សាសន្តិសុខ និងចែកជូនដល់ប្រទេសសមាជិក អង្គការ សហប្រជាជាតិទាំងអស់

១៧. នៅក្នុងស្ថានភាពសមរម្យណាមួយ ស្នើអោយអគ្គលេខាធិការអង្គការសហប្រជាជាតិ បញ្ចូលការចំនុចស្តីពីការរីកចំរើនក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងបេសកកម្មរក្សាសន្តិភាព និងនៅក្នុងទិដ្ឋភាពដទៃទាំងឡាយ ណាដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារី

១៨. សំរេចរក្សាការប្រកាន់យកនូវបញ្ហានេះដោយសកម្ម ។